ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់យន្តការសម្រាប់អនុវត្តកម្មវិធីភាគព្វកិច្ចសេវាសកលវិស័យទូរគមនាគមន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលមាត្រា២៦ មាត្រា២៧ មាត្រា២៨ និងមាត្រា២៩ និងបំពេញបន្ថែមមាត្រា២៩ ស្ទួន នៃអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ មានគោលបំណងជានាការគ្រប់គ្រងនិងការអនុវត្តកម្មវិធីកាតព្វកិច្ចសេវាសកលវិស័យទូរគមនា-គមន៍ ដែលត្រូវស្ថិតនៅក្រោមការគ្រប់គ្រង ការចាត់ចែង និងការទទួលខុសត្រូវរបស់ "ក្រុមប្រឹក្សាភិបាលមូលនិធិកាតព្វកិច្ចសេវាសកលទូរគមនាគមន៍" ដែលសរសេរជាអក្សរកាត់ថា "**ក.ម.ក.ស.ទ.**" ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពី៖

- យន្តការអនុវត្តមូលនិធិកាតព្វកិច្ចសេវាសកលទូរគមនាគមន៍
- ការប្រមូលនិងការប្រើប្រាស់មូលនិធិកាតព្វកិច្ចសេវាសកលទូរគមនាគមន៍
- លក្ខខណ្ឌនិងនីតិវិធីនៃការផ្ដល់មូលនិធិកាតព្វកិច្ចសេវាសកលទូរគមនាគមន៍
- លក្ខខណ្ឌនិងនីតិវិធីនៃការទូទាត់រវាងវិភាគទានមូលនិធិជាមួយនឹងគម្រោងអនុវត្តកម្មវិធីកាតព្វកិច្ចសេវាសកលទូរគមនាគមន៍
- ការត្រួតពិនិត្យ ការតាមដាន និងការវាយតម្លៃការប្រើប្រាស់មូលនិធិកាតព្វកិច្ចសេវាសកលទូរគមនាគមន៍។

**មាត្រា៣ .-**

អនុក្រឹត្យនេះ មានវិសាលភាពគ្របដណ្ដប់លើការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់មូលនិធិកាតព្វកិច្ចសេវាសកលទូរគមនាគមន៍ ស្របតាមច្បាប់ស្ដីពីទូរគមនាគមន៍នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ .-**

និយមន័យនៃពាក្យបច្ចេកទេសក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

**កាតព្វកិច្ចសេវាសកលទូរគមនាគមន៍** តទៅសរសេរជាអក្សរកាត់ថា "**ក.ស.ទ.**"។

**ចំណូលដុល** សំដៅដល់ប្រាក់ចំណូលទាំងអស់របស់ប្រតិបត្តិករទូរគមនាគមន៍ ដែលបានមកពីប្រតិបត្តិការទូរគមនាគមន៍ ស្របតាមច្បាប់ស្ដីពីទូរគមនាគមន៍ ដោយមិនទាន់កាត់កងចំណាយណាទាំងអស់ លើកលែងតែចំណូលពីការលក់គ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍។

**មូលនិធិកាតព្វកិច្ចសេវាសកលទូរគមនាគមន៍** សំដៅដល់សំណុំនៃថវិកាទាំងឡាយដែលប្រើប្រាស់ដើម្បីទ្រទ្រង់ និងអនុវត្តកម្មវិធីកាតព្វកិច្ចសេវាសកល តទៅសរសេរកាត់ថា "មូលនិធិ **ក.ស.ទ.**" ។

**ផល** សំដៅដល់អ្វីៗដែលកើតឡើងពីការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ និងបណ្ដាញទូរគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រវិស័យទូរគមនាគមន៍ ឬការកសាង ការផ្ដល់ និងការពង្រឹងសេវាទូរគមនាគមន៍និងសេវាបច្ចេក-វិទ្យាគមនាគមន៍និងព័ត៌មាន។

# ជំពូកទី២
# ការគ្រប់គ្រងមូលនិធិភាតព្វកិច្ចសេវាសកលទូរគមនាគមន៍
## ផ្នែកទី១
## ក្រុមប្រឹក្សាភិបាលមូលនិធិភាតព្វកិច្ចសេវាសកលទូរគមនាគមន៍

**មាត្រា៥ .-**

**ក.ម.ភ.ស.ទ.** មានសមាសភាពចំនួន ០៧ (ប្រាំពីរ) រូប ដូចខាងក្រោម ៖

| | | |
|---|---|---|
| - រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ១ រូប | អនុប្រធានទី១ |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១ រូប | អនុប្រធានទី២ |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍ | | សមាជិកអចិន្ត្រៃយ៍ |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន | | សមាជិក |
| - ប្រធានវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន | | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១ រូប | សមាជិក |

សមាសភាពជាក់ស្តែងរបស់ **ក.ម.ភ.ស.ទ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៦ .-**

**ក.ម.ភ.ស.ទ.** មានមុខងារនិងភារកិច្ច ដូចខាងក្រោម៖

- គ្រប់គ្រងនិងចាត់ចែងមូលនិធិ **ភ.ស.ទ.**
- លើកកម្ពស់និងជំរុញការអនុវត្ត **ភ.ស.ទ.** ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព
- ពិនិត្យនិងអនុម័តកម្មវិធី **ភ.ស.ទ.**
- ពិនិត្យនិងអនុម័តលើផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាព **ភ.ស.ទ.**
- ពិនិត្យនិងអនុម័តលើផែនការនិងយន្តការអនុវត្តកម្មវិធី **ភ.ស.ទ.** ក្នុងរយៈពេលខ្លី មធ្យម និងរយៈពេលវែង
- ពិនិត្យនិងអនុម័តលើយន្តការទូទាត់គម្រោងអនុវត្តកម្មវិធី **ភ.ស.ទ.**
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព **ភ.ស.ទ.**
- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាព **ភ.ស.ទ.** ជូនរាជរដ្ឋាភិបាល
- ផ្តល់យោបល់ជូនរាជរដ្ឋាភិបាលអំពីវិភាគទានពីប្រតិបត្តិករទូរគមនាគមន៍ដែលត្រូវចូលរួមក្នុងមូលនិធិ **ភ.ស.ទ.**
- ធ្វើជាតំណាងស្របច្បាប់របស់មូលនិធិ **ភ.ស.ទ.** ក្នុងទំនាក់ទំនងជាមួយក្រសួង ស្ថាប័នរដ្ឋឬឯកជន
- ពិនិត្យនិងអនុម័តការផ្តល់ ការបន្ត ការផ្អាក ការផ្ទេរ ឬការបញ្ឈប់គម្រោងអនុវត្តកម្មវិធី **ភ.ស.ទ.**
- ពិនិត្យនិងអនុម័តថវិកាសម្រាប់គម្រោងអនុវត្តកម្មវិធី **ភ.ស.ទ.**
- ពិនិត្យនិងអនុម័តថវិកាប្រចាំឆ្នាំរបស់មូលនិធិ **ភ.ស.ទ.** និង
- អនុម័តលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់មូលនិធិ **ភ.ស.ទ.**។

**មាត្រា៧ ..**

**គ.ម.ក.ស.ឧ.** អាចមានអ្នកជំនាញការជាតិឬអន្តរជាតិមួយចំនួន ដែលមានសមត្ថភាព ជំនាញ និងបទពិសោធន៍ខ្ពស់ ដើម្បីជួយបម្រើការងារជាទីប្រឹក្សាបច្ចេកទេស។

**មាត្រា៨ ..**

**គ.ម.ក.ស.ឧ.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (**ក.ប.ឧ.**)។

## ផ្នែកទី២
## ដំណើរការរបស់ក្រុមប្រឹក្សាភិបាលមូលនិធិកាតព្វកិច្ចសេវាសកលទូរគមនាគមន៍

**មាត្រា៩ ..**

**គ.ម.ក.ស.ឧ.** មានរបបប្រជុំសាមញ្ញប្រចាំត្រីមាស និងប្រចាំឆ្នាំ ព្រមទាំងអាចប្រជុំវិសាមញ្ញ តាមគំនិតផ្តួចផ្តើមរបស់ប្រធាន **គ.ម.ក.ស.ឧ.** ឬតាមការស្នើសុំពីសមាជិកក្រុមប្រឹក្សាភិបាលចំនួន ២/៣ (ពីរភាគបី)។

**គ.ម.ក.ស.ឧ.** ត្រូវដំណើរការពិភាក្សាលើរបៀបវារៈដែលបានគ្រោង។ របៀបវារៈ ត្រូវបានជូនដំណឹងជាមុនយ៉ាងតិច ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការដល់គ្រប់សមាជិក **គ.ម.ក.ស.ឧ.**។

**គ.ម.ក.ស.ឧ.** អាចអញ្ជើញភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំតាមការចាំបាច់។

**មាត្រា១០ ..**

**គ.ម.ក.ស.ឧ.** អាចដំណើរការប្រជុំបានលុះត្រាតែមានសមាជិកលើសពី ៥០% (ហាសិបភាគរយ) ចូលរួម។ សមាជិក **គ.ម.ក.ស.ឧ.** ដែលអវត្តមានពុំអាចចាត់តំណាងជំនួសបានឡើយ។

កិច្ចប្រជុំ **គ.ម.ក.ស.ឧ.** ត្រូវធ្វើឡើងក្រោមអធិបតីភាពរបស់ប្រធានឬប្រធានស្តីទី **គ.ម.ក.ស.ឧ.**។ ក្នុងករណីដែលប្រធានអវត្តមាន អនុប្រធានទី១ **គ.ម.ក.ស.ឧ.** ត្រូវបំពេញតួនាទីជាប្រធានស្តីទី។

សមាជិកអង្គប្រជុំទាំងអស់ដែលចូលរួមប្រជុំ **គ.ម.ក.ស.ឧ.** ត្រូវចុះហត្ថលេខាលើបញ្ជីវត្តមាន។

**មាត្រា១១ ..**

សេចក្តីសម្រេចរបស់ **គ.ម.ក.ស.ឧ.** ត្រូវអនុម័តតាមមតិភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធាននៃអង្គប្រជុំមានឧត្តមានុភាព។

សេចក្តីសម្រេចរបស់ **គ.ម.ក.ស.ឧ.** ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវរក្សាទុកនៅលេខាធិការដ្ឋាននៃ **គ.ម.ក.ស.ឧ.** ដោយមានចុះហត្ថលេខារបស់ប្រធានអង្គប្រជុំ។

កិច្ចប្រជុំ **គ.ម.ក.ស.ឧ.** ត្រូវកត់ត្រាក្នុងកំណត់ហេតុ។ កំណត់ហេតុ ត្រូវឆ្លុះបញ្ចាំងពីភាពពិតនៃការពិភាក្សារបស់អង្គប្រជុំ។ លេខានៃអង្គប្រជុំ **គ.ម.ក.ស.ឧ.** ត្រូវរៀបចំនិងផ្ញើសេចក្តីព្រាងកំណត់ហេតុជូនសមាជិក **គ.ម.ក.ស.ឧ.** ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំនីមួយៗ។ សមាជិក **គ.ម.ក.ស.ឧ.** មានរយៈពេល ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទទទួលបានកំណត់ហេតុប្រជុំដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវ ឬផ្តល់មតិកែសម្រួលលើកំណត់ហេតុ។ ក្នុងរយៈពេល ១២ (ដប់ពីរ) ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទនៃកិច្ចប្រជុំ ប្រធាន **គ.ម.ក.ស.ឧ.** ចុះហត្ថលេខាលើកំណត់ហេតុដែលទទួលបានការកែតម្រូវ ឬការយល់ព្រមពីសមាជិក **គ.ម.ក.ស.ឧ.** ទាំងអស់ដែលមានវត្តមានក្នុងកិច្ចប្រជុំ។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗជូនប្រធាន អនុប្រធាន និងសមាជិក **គ.ម.ក.ស.ឧ.** ត្រូវសម្រេចជាគោលការណ៍ដោយរដ្ឋមន្ត្រី **ក.ប.ឧ.** និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ **គ.ម.ក.ស.ឧ.**។

## ផ្នែកទី៣
## លេខាធិការដ្ឋាននៃក្រុមប្រឹក្សាភិបាលមូលនិធិភាគព្វកិច្ចសេវាសកលទូរគមនាគមន៍

**មាត្រា១២ ..**

ត្រូវបង្កើតលេខាធិការដ្ឋាននៃ **ក.ម.ក.ស.ទ.** ជាសេនាធិការរបស់ **ក.ម.ក.ស.ទ.**។ លេខាធិការដ្ឋាននៃ **ក.ម.ក.ស.ទ.** ត្រូវដឹកនាំដោយសមាជិកអចិន្ត្រៃយ៍ **ក.ម.ក.ស.ទ.** និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

**មាត្រា១៣ ..**

លេខាធិការដ្ឋាននៃ **ក.ម.ក.ស.ទ.** មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- ពិនិត្យ សិក្សា ស្រាវជ្រាវ និងវិភាគលើស្ថានភាពនៃការអភិវឌ្ឍវិស័យទូរគមនាគមន៍ ដើម្បីរៀបចំសមិទ្ធិ-លទ្ធភាពខាងផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុនៃកម្មវិធី **ក.ស.ទ.**
- រៀបចំកម្មវិធី **ក.ស.ទ.** ជូន **ក.ម.ក.ស.ទ.** ដើម្បីពិនិត្យនិងសម្រេច
- រៀបចំផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាព **ក.ស.ទ.** ជូន **ក.ម.ក.ស.ទ.** ដើម្បីពិនិត្យនិងសម្រេច
- រៀបចំផែនការនិងយន្តការអនុវត្តកម្មវិធី **ក.ស.ទ.** ក្នុងរយៈពេលខ្លី មធ្យម និងរយៈពេលវែង ជូន **ក.ម.ក.ស.ទ.** ដើម្បីពិនិត្យនិងសម្រេច
- រៀបចំយន្តការទូទាត់គម្រោងអនុវត្តកម្មវិធី **ក.ស.ទ.** ជូន **ក.ម.ក.ស.ទ.** ដើម្បីពិនិត្យនិងសម្រេច
- រៀបចំ និងសម្របសម្រួលការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តកម្មវិធី **ក.ស.ទ.** ជូន **ក.ម.ក.ស.ទ.**
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគម្រោងអនុវត្តកម្មវិធី **ក.ស.ទ.** តាមការណែនាំរបស់ **ក.ម.ក.ស.ទ.**
- រៀបចំ និងសម្របសម្រួលការបន្ត ការផ្អាក ការផ្ទេរ ឬការបញ្ឈប់គម្រោងអនុវត្តកម្មវិធី **ក.ស.ទ.** ជូន **ក.ម.ក.ស.ទ.** ដើម្បីពិនិត្យនិងសម្រេច
- រៀបចំថវិកាសម្រាប់អនុវត្តកម្មវិធី **ក.ស.ទ.** ជូន **ក.ម.ក.ស.ទ.** ដើម្បីពិនិត្យនិងសម្រេច
- រៀបចំថវិកាប្រចាំឆ្នាំរបស់ **ក.ម.ក.ស.ទ.** ជូន **ក.ម.ក.ស.ទ.** ដើម្បីពិនិត្យនិងសម្រេច
- ប្រមូល និងផ្ទៀងផ្ទាត់ការបង់វិភាគទានរបស់ប្រតិបត្តិករទូរគមនាគមន៍ចូលមូលនិធិ **ក.ស.ទ.**
- ពិនិត្យ ផ្ទៀងផ្ទាត់ ទូទាត់ និងផាត់ទាត់ការប្រើប្រាស់មូលនិធិ **ក.ស.ទ.**
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍សកម្មភាពប្រចាំឆ្នាំស្តីពីការអនុវត្ត **ក.ស.ទ.** ជូន **ក.ម.ក.ស.ទ.** ដើម្បីពិនិត្យនិងសម្រេច
- តាមដានលំហូរធនធាននៃមូលនិធិ **ក.ស.ទ.** ដែលបានមកពីប្រភពផ្សេងៗទាំងក្នុងនិងក្រៅប្រទេស
- រៀបចំផែនការចំណូលនិងចំណាយជូន **ក.ម.ក.ស.ទ.** ដើម្បីពិនិត្យនិងសម្រេច
- រាយការណ៍អំពីវឌ្ឍនភាពនៃការប្រើប្រាស់មូលនិធិ **ក.ស.ទ.** និងស្នើសុំ **ក.ម.ក.ស.ទ.** ចាត់វិធានការនានាចំពោះបុគ្គលទទួលបានគម្រោងអនុវត្តកម្មវិធី **ក.ស.ទ.** ដែលមិនអនុវត្ត ឬអនុវត្តមិនពេញលេញនូវ **ក.ស.ទ.**
- ផ្សព្វផ្សាយផែនការអនុវត្តកម្មវិធី **ក.ស.ទ.**
- រៀបចំ សម្របសម្រួល និងធ្វើកំណត់ហេតុរាល់កិច្ចប្រជុំពិភាក្សារបស់ **ក.ម.ក.ស.ទ.**
- សម្របសម្រួលការងាររដ្ឋបាលទូទៅនិងគ្រប់គ្រងថែរក្សាមូលនិធិ **ក.ស.ទ.**

- គ្រប់គ្រងបុគ្គលិកនិងមន្ត្រីទទួលបន្ទុកសម្របសម្រួលការងាររដ្ឋបាលនិងគ្រប់គ្រងមូលនិធិ **ក.ស.ឧ.**
- រាយការណ៍និងផ្តល់យោបល់ជូន **ក.ម.ក.ស.ឧ.** នូវរាល់បញ្ហាពាក់ព័ន្ធនឹងការគ្រប់គ្រងមូលនិធិ **ក.ស.ឧ.** និង
- តួនាទីនិងភារកិច្ចផ្សេងទៀតដែល **ក.ម.ក.ស.ឧ.** ប្រគល់ជូន។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃ **ក.ម.ក.ស.ឧ.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ឧ.**។

**មាត្រា១៤ ..**

បន្ទាប់ពីទទួលបានការអនុញ្ញាតពី **ក.ម.ក.ស.ឧ.** លេខាធិការដ្ឋាននៃ **ក.ម.ក.ស.ឧ.** អាចពិគ្រោះយោបល់ជាមួយប្រតិបត្តិករទូរគមនាគមន៍និងបុគ្គលពាក់ព័ន្ធ មុននឹងដាក់សេចក្តីព្រាងកម្មវិធីនិងផែនការអនុវត្តកម្មវិធី **ក.ស.ឧ.** ទៅ **ក.ម.ក.ស.ឧ.**។

**មាត្រា១៥ ..**

**ក.ម.ក.ស.ឧ.** ត្រូវមានកញ្ចប់ថវិកាសម្រាប់ដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួន។ ថវិកានេះ ត្រូវដកចេញពីមូលនិធិ **ក.ស.ឧ.** ប្រចាំឆ្នាំ យ៉ាងច្រើនចំនួន ១០% (ដប់ភាគរយ)។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗជូនមន្ត្រីដែលបម្រើការងារក្នុងលេខាធិការដ្ឋាននៃ **ក.ម.ក.ស.ឧ.** ត្រូវសម្រេចជាគោលការណ៍ដោយ **ក.ម.ក.ស.ឧ.** តាមសំណើរបស់ប្រធានលេខាធិការដ្ឋាន។

## ជំពូកទី៣
## ការប្រមូលនិងការប្រើប្រាស់មូលនិធិកាតព្វកិច្ចសេវាសកលទូរគមនាគមន៍

**មាត្រា១៦ ..**

ប្រភពធនធាននៃមូលនិធិ **ក.ស.ឧ.** រួមមាន៖

- ការបង់វិភាគទានរៀងរាល់ឆ្នាំចំនួន ០២% (ពីរភាគរយ) នៃចំណូលដុលដោយប្រតិបត្តិករទូរគមនា-គមន៍ ស្របតាមច្បាប់ស្តីពីទូរគមនាគមន៍
- ធនធានដែលរដ្ឋឬក្រសួង ស្ថាប័ន ផ្តល់ឱ្យមូលនិធិ **ក.ស.ឧ.** សម្រាប់គម្រោងរួមគ្នា
- ធនធានដែលបានមកពីដៃគូអភិវឌ្ឍន៍
- ហិរញ្ញប្បទានសហប្រតិបត្តិការបរទេសនិងប្រភពផ្សេងទៀតសម្រាប់ចំណាយលើសេវារដ្ឋបាល និងសម្រាប់បម្រើដល់សេចក្តីត្រូវការក្នុងការផ្គត់ផ្គង់សម្ភារៈបរិក្ខារនិងការឧបត្ថម្ភផ្សេងៗ តាមការចាំបាច់ក្នុងគោលដៅធានាប្រសិទ្ធភាពក្នុងការបំពេញមុខងារ និង
- ប្រភពផ្សេងទៀត។

ប្រភពធនធាននៃមូលនិធិ **ក.ស.ឧ.** ត្រូវដាក់ចូលក្នុងគណនីប្រាក់បញ្ញើរបស់មូលនិធិ **ក.ស.ឧ.** នៅធនាគារជាតិ លើកលែងតែមានការកំណត់ផ្សេងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ប្រតិបត្តិករទូរគមនាគមន៍ត្រូវចាប់ផ្តើមបង់វិភាគទានចូលមូលនិធិ **ក.ស.ឧ.** ចាប់ពីឆ្នាំ២០១៧ តទៅ។

**មាត្រា១៧ ..**

ប្រតិបត្តិករទូរគមនាគមន៍ត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលធ្វើសវនកម្មរួចមក **ក.ម.ក.ស.ឧ.** យ៉ាងយូរបំផុត ៩០ (កៅសិប) ថ្ងៃ ក្រោយការិយបរិច្ឆេទនៃឆ្នាំនីមួយៗ។

ប្រតិបត្តិករទូរគមនាគមន៍ត្រូវបង់វិភាគទានចំនួន ០២% (ពីរភាគរយ) នៃចំណូលដុល ដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលធ្វើសវនកម្មរួច។ ចំនួនទឹកប្រាក់បង់វិភាគទាននេះ ត្រូវគណនាដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៃឆ្នាំចាស់។ ប្រាក់លម្អៀងនៃការគណនាទឹកប្រាក់បង់វិភាគទាននៃឆ្នាំចាស់ និងឆ្នាំដែលត្រូវបង់ នឹងត្រូវធ្វើនិយ័តកម្ម បន្ទាប់ពីទទួលបានរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដូចមានចែងក្នុងកថាខណ្ឌទី១។

ប្រតិបត្តិករទូរគមនាគមន៍ត្រូវបង់វិភាគទានផ្ទាល់ទៅក្នុងគណនីមូលនិធិ **ក.ស.ឌ.** យ៉ាងយូរ ៣០ (សាមសិប) ថ្ងៃបន្ទាប់ពីទទួលបានសេចក្តីសម្រេចរបស់ **ក.ម.ក.ស.ឌ.** អំពីចំនួនទឹកប្រាក់ដែលត្រូវបង់ចូលមូលនិធិ **ក.ស.ឌ.**។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបង់វិភាគទានចូលមូលនិធិ **ក.ស.ឌ.** ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រី **ក.ប.ឌ.** និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

សំណល់ក្នុងឆ្នាំចាស់នៃមូលនិធិ **ក.ស.ឌ.** ត្រូវយោងទៅប្រើប្រាស់ជាមួយមូលនិធិ **ក.ស.ឌ.** ឆ្នាំបន្ទាប់។

**មាត្រា១៨ .-**

ប្រតិបត្តិករទូរគមនាគមន៍អាចស្នើសុំការទូទាត់ជាមុនរវាងវិភាគទានមូលនិធិ **ក.ស.ឌ.** ជាមួយនឹងគម្រោងអនុវត្តកម្មវិធី **ក.ស.ឌ.** ចំនួន ៥០% (ហាសិបភាគរយ) នៃកាតព្វកិច្ចបង់វិភាគទានមូលនិធិ **ក.ស.ឌ.** ប្រចាំឆ្នាំ។

ដើម្បីអាចស្នើសុំទូទាត់ជាមុនរវាងវិភាគទានមូលនិធិ **ក.ស.ឌ.** ជាមួយនឹងគម្រោងអនុវត្តកម្មវិធី **ក.ស.ឌ.** ដូចមានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើ ប្រតិបត្តិករទូរគមនាគមន៍ ត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវដាក់ពាក្យស្នើសុំជាមុនទៅ **ក.ម.ក.ស.ឌ.** យ៉ាងយូរត្រឹមត្រីមាសទីមួយនៃឆ្នាំនីមួយៗ
- ត្រូវភ្ជាប់នូវរបាយការណ៍លម្អិតនៃការអនុវត្តគម្រោងអនុវត្តកម្មវិធី **ក.ស.ឌ.**
- ត្រូវគោរពតាមផែនការសកម្មភាពនៃការអនុវត្តកម្មវិធី **ក.ស.ឌ.**
- ត្រូវអនុវត្តកាតព្វកិច្ចទាំងឡាយដូចមានកំណត់ក្នុងមាត្រា២៤ នៃអនុក្រឹត្យនេះ
- តាមការកំណត់ផ្សេងទៀតដោយ **ក.ម.ក.ស.ឌ.**។

**មាត្រា១៩ .-**

**ក.ម.ក.ស.ឌ.** មានសិទ្ធិអនុម័តការទូទាត់រវាងវិភាគទានមូលនិធិ **ក.ស.ឌ.** ប្រចាំឆ្នាំនិងការអនុវត្តគម្រោងអនុវត្តកម្មវិធី **ក.ស.ឌ.**។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការទូទាត់រវាងវិភាគទានមូលនិធិ **ក.ស.ឌ.** ជាមួយនឹងការអនុវត្តកម្មវិធី **ក.ស.ឌ.** ត្រូវកំណត់បន្ថែមដោយ **ក.ម.ក.ស.ឌ.**។

**មាត្រា២០ .-**

មូលនិធិ **ក.ស.ឌ.** ត្រូវបានប្រើប្រាស់ដើម្បីជំរុញការកាត់បន្ថយគម្លាតឌីជីថល ក្នុងការចូលរួមអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។ កម្មវត្ថុនៃការប្រើប្រាស់មូលនិធិ **ក.ស.ឌ.** មានជាអាទិ៍ ដូចខាងក្រោម៖

ក- កសាងនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញទូរគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រវិស័យទូរគមនាគមន៍សម្រាប់អ៊ីនធឺណិតល្បឿនលឿនជាអាទិភាពទៅ៖

  - រដ្ឋបាលថ្នាក់ក្រោមជាតិ
  - តំបន់ជនបទ
  - តំបន់ដែលប្រជាជនមានចំណូលទាបជាងប្រាក់ឈ្នួលអប្បបរមាដែលត្រូវបានធានាសម្រាប់កម្មករនិយោជិត
  - គ្រឹះស្ថានសិក្សាសាធារណៈឬគ្រឹះស្ថានសិក្សាឥតគិតថ្លៃ

- គ្រឹះស្ថានស្រាវជ្រាវសាធារណៈឬគ្រឹះស្ថានស្រាវជ្រាវឥតគិតថ្លៃ
- បណ្ណាល័យជាតិ បណ្ណាល័យរាជធានី-ខេត្ត ឬបណ្ណាល័យឥតគិតថ្លៃ
- មន្ទីរពេទ្យសាធារណៈឬមន្ទីរពេទ្យឥតគិតថ្លៃ ឬ
- មណ្ឌលសុខភាពសាធារណៈឬមណ្ឌលសុខភាពឥតគិតថ្លៃ។

ខ- ផ្តល់ ពង្រឹង និងពង្រីកសេវាទូរគមនាគមន៍និងសេវាបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានទំនើបនិងល្បឿនលឿននៅតំបន់អាទិភាពដែលបានកំណត់ក្នុងចំណុច (ក) នៃមាត្រានេះ ប្រកបដោយសុវត្ថិភាពនិងសន្តិសុខ

ឃ- ផ្តល់សេវាគ្រាអាសន្នទូទាំងប្រទេសដោយឥតគិតថ្លៃ

ង- ចំណាយរដ្ឋបាល និង

ច- កម្មវត្ថុផ្សេងទៀតដែលកំណត់ដោយ **គ.ម.គ.ស.ទ.**។

**មាត្រា២១ ..**

ផលដែលកើតឡើងពីការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញទូរគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រវិស័យទូរគមនាគមន៍ ឬការផ្តល់ ការពង្រឹង និងការពង្រីកសេវាទូរគមនាគមន៍និងសេវាបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនិងការប្រើប្រាស់នៃបុគ្គលដែលទទួលបានគម្រោងអនុវត្តកម្មវិធី **គ.ស.ទ.** ស្របតាមអនុក្រឹត្យនេះនិងបទប្បញ្ញត្តិផ្សេងទៀត។

**មាត្រា២២ ..**

រាល់ចំណាយចំពោះធនធានមនុស្សនិងសម្ភារៈសម្រាប់ដំណើរការ និងការបំពេញភារកិច្ចរបស់ **គ.ម.គ.ស.ទ.** និងលេខាធិការដ្ឋាននៃ **គ.ម.គ.ស.ទ.** គឺជាចំណាយរដ្ឋបាល មានជាអាទិ៍៖

- ប្រាក់សម្រាប់ដំណើរការនិងបំពេញភារកិច្ចរបស់ **គ.ម.គ.ស.ទ.** និងលេខាធិការដ្ឋាន
- ប្រាក់ឧបត្ថម្ភសម្រាប់សមាជិក **គ.ម.គ.ស.ទ.**
- ប្រាក់ឧបត្ថម្ភសម្រាប់ប្រធាន អនុប្រធាន ទីប្រឹក្សាបច្ចេកទេស មន្ត្រីរាជការ និងបុគ្គលិកនៃលេខាធិការដ្ឋាន
- ការទិញ ការជួល ការជួសជុល ឬការថែទាំសង្ហារឹម សម្ភារៈការិយាល័យ មធ្យោបាយនិងសម្ភារៈរដ្ឋបាល
- ការទិញ ការជួល ការជួសជុល ឬការថែទាំយានជំនិះ
- ចំណាយចំពោះប្រេងឥន្ធនៈ ប្រេងរំអិល និង
- ចំណាយជាក់ស្តែងផ្សេងៗទៀតតាមការកំណត់របស់ **គ.ម.គ.ស.ទ.**។

## ជំពូកទី៤
## លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់មូលនិធិនិងការទូទាត់រំលងវិភាគទានមូលនិធិជាមួយនឹងគម្រោងអនុវត្តកម្មវិធីកាតព្វកិច្ចសេវាសកលទូរគមនាគមន៍

**មាត្រា២៣ ..**

បុគ្គលដែលមានសិទ្ធិស្នើសុំមូលនិធិ **គ.ស.ទ.** ឬស្នើសុំការទូទាត់រំលងវិភាគទានមូលនិធិ **គ.ស.ទ.** ជាមួយនឹងគម្រោងអនុវត្តកម្មវិធី **គ.ស.ទ.** មានដូចខាងក្រោម៖

- ប្រតិបត្តិករទូរគមនាគមន៍ដែលបានបំពេញប្រតិបត្តិការដូចមានចែងក្នុងមាត្រា១៧ នៃច្បាប់ស្តីពីទូរគមនា-គមន៍ និងបានអនុវត្តកាតព្វកិច្ចស្របតាមបទប្បញ្ញត្តិជាធរមាន
- អង្គភាពរដ្ឋទទួលបន្ទុកអភិវឌ្ឍន៍វិស័យទូរគមនាគន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

- បុគ្គលផ្សេងទៀតដែលមានគុណវុឌ្ឍិឆ្លើយតបទៅនឹងកម្មវត្ថុណាមួយដូចមានចែងក្នុងមាត្រា២០ នៃអនុក្រឹត្យនេះ។

**មាត្រា២៤.-**

ដើម្បីទទួលបានមូលនិធិ **ក.ស.ឧ.** ឬការទូទាត់រំលងវិភាគទានមូលនិធិ **ក.ស.ឧ.** ជាមួយនឹងគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.** អ្នកស្នើសុំត្រូវបញ្ជាក់ថា៖

- បានអនុវត្តកាតព្វកិច្ចបង់វិភាគទានដោយប្រតិបត្តិករទូរគមនាគមន៍ចូលមូលនិធិ **ក.ស.ឧ.** ស្របតាមអនុក្រឹត្យនេះនិងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត
- ពុំមានជាប់បំណុលដោយខកខានបង់វិភាគទានចូលមូលនិធិ **ក.ស.ឧ.**
- មានសក្តានុពលភាពផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងមានឆន្ទៈក្នុងការសម្រេចនូវគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.**
- ចំពោះបុគ្គលស្នើសុំមូលនិធិ **ក.ស.ឧ.**៖ ត្រូវផ្តល់នូវគម្រោងបច្ចេកទេសនិងហិរញ្ញវត្ថុ និងគោរពតាមលក្ខខណ្ឌ បែបបទ និងនីតិវិធីដែលកំណត់ដោយ **ក.ម.ក.ស.ឧ.**
- ចំពោះបុគ្គលស្នើសុំទូទាត់រំលងវិភាគទានមូលនិធិ **ក.ស.ឧ.** ជាមួយនឹងគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.**៖ ត្រូវភ្ជាប់គម្រោងបច្ចេកទេសនិងហិរញ្ញវត្ថុអនុវត្តគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.** ដែលឆ្លើយតបយ៉ាងជាក់ស្តែងទៅនឹងផែនការអាទិភាពប្រចាំឆ្នាំនៃគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.** និងបានធ្វើសវនកម្មរួច និង
- បង់ថ្លៃសេវាទទួលសិក្សានិងសម្រេចលើគម្រោងដែលបានស្នើសុំមក **ក.ម.ក.ស.ឧ.** ស្របតាមប្រកាសរួមរបស់ **ក.ប.ឧ.** និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៥.-**

បុគ្គលទាំងឡាយដែលទទួលបានគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.** អាចប្រើប្រាស់ថវិកានៃគម្រោងនេះដើម្បីស្ថាបនានិងប្រតិបត្តិការលើផលដែលកើតឡើងពីការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញទូរគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រវិស័យទូរគមនាគមន៍ ឬការផ្តល់ ការពង្រឹង និងការពង្រីកសេវាទូរគមនាគមន៍និងសេវាបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។

**មាត្រា២៦.-**

គម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.** ត្រូវបានផ្តល់តាមករណីដូចខាងក្រោម៖

ក- ករណីសំណើសុំគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.** តាមរយៈការផ្សព្វផ្សាយជាសាធារណៈ៖

- លេខាធិការដ្ឋាននៃ **ក.ម.ក.ស.ឧ.** ត្រូវប្រកាសរកបុគ្គលអនុវត្តគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.** តាមការផ្សព្វផ្សាយជាសាធារណៈ
- **ក.ម.ក.ស.ឧ.** អាចជ្រើសរើសយកវិធីដាក់ឱ្យដេញថ្លៃគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.** ឬជ្រើសរើសយកបុគ្គលអនុវត្តគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.** ស្របតាមការកំណត់ក្នុងអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត
- បុគ្គលស្នើសុំគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.** ត្រូវផ្តល់នូវគម្រោងបច្ចេកទេសនិងហិរញ្ញវត្ថុលម្អិត និងគោរពតាមលក្ខខណ្ឌនិងនីតិវិធីដែលកំណត់ដោយ **ក.ម.ក.ស.ឧ.**

- **គ.ម.គ.ស.ឧ.** ត្រូវសម្រេចផ្ដល់គម្រោងអនុវត្តកម្មវិធី **គ.ស.ឧ.** ដល់បុគ្គលដែលបានស្នើសុំគម្រោងអនុវត្តកម្មវិធី **គ.ស.ឧ.** បន្ទាប់ពីបានពិនិត្យ និងវាយតម្លៃលើសំណុំឯកសារតាមលក្ខខណ្ឌនិងនីតិវិធីជាធរមាន
- សេចក្ដីសម្រេចរបស់ **គ.ម.គ.ស.ឧ.** អាចត្រូវបានតវ៉ាទៅតុលាការមានសមត្ថកិច្ច ដោយបុគ្គលស្នើសុំគម្រោងអនុវត្តកម្មវិធី **គ.ស.ឧ.** ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្ដីសម្រេច។ សេចក្ដីសម្រេចរបស់ **គ.ម.គ.ស.ឧ.** ត្រូវបិទផ្លូវតវ៉ា ក្នុងករណីដែលបុគ្គលស្នើសុំគម្រោងអនុវត្តកម្មវិធី **គ.ស.ឧ.** មិនបានតវ៉ាក្នុងរយៈពេលកំណត់នេះ។

ខ- ករណីស្នើសុំទូទាត់រវាងវិភាគទានមូលនិធិ **គ.ស.ឧ.** ជាមួយនឹងគម្រោងអនុវត្តកម្មវិធី **គ.ស.ឧ.**៖

- នីតិវិធីដែលកំណត់ក្នុងចំណុច (ក) ខាងលើ ត្រូវយកមកអនុវត្តដូចគ្នា
- **គ.ម.គ.ស.ឧ.** មានសិទ្ធិសម្រេចដាក់ឱ្យដេញថ្លៃក្នុងករណីដែលមានសំណើច្រើនលើការទូទាត់រវាងវិភាគទានមូលនិធិ **គ.ស.ឧ.** ជាមួយនឹងគម្រោងអនុវត្តកម្មវិធី **គ.ស.ឧ.** ដូចគ្នា។

រាល់គម្រោងអនុវត្តកម្មវិធី **គ.ស.ឧ.** ដែលត្រូវបានអនុម័តយល់ព្រមដោយ **គ.ម.គ.ស.ឧ.** ត្រូវផ្សព្វផ្សាយជាសាធារណៈ។

**មាត្រា២៧ ..**

ការផ្ដល់ថវិកាដល់បុគ្គលអនុវត្តគម្រោងអនុវត្តកម្មវិធី **គ.ស.ឧ.** ត្រូវធ្វើឡើងតាមរយៈការផ្ទេររវាងគណនីធនាគារ និងតាមដំណាក់កាល ស្របតាមការសម្រេចនៃគម្រោងអនុវត្តកម្មវិធី **គ.ស.ឧ.** ដោយភ្ជាប់មកជាមួយនូវរបាយការណ៍លម្អិតនៃការសម្រេចគម្រោង។ នីតិវិធីនៃការផ្ដល់ថវិកានេះអាចត្រូវបានកំណត់បន្ថែមដោយសេចក្ដីសម្រេចរបស់ **គ.ម.គ.ស.ឧ.**។

## ជំពូកទី៥
## ការត្រួតពិនិត្យ ការតាមដាន និងការវាយតម្លៃ
## ការប្រើប្រាស់មូលនិធិភាគព្វកិច្ចសេវាសកលទូរគមនាគមន៍

**មាត្រា២៨ ..**

បុគ្គលទទួលបានគម្រោងអនុវត្តកម្មវិធី **គ.ស.ឧ.** ត្រូវរៀបចំរបាយការណ៍ស្ដីពីវឌ្ឍនភាពនៃការអនុវត្តគម្រោងអនុវត្តកម្មវិធី **គ.ស.ឧ.** តាមការស្នើសុំរបស់លេខាធិការដ្ឋាននៃ **គ.ម.គ.ស.ឧ.**។

បុគ្គលទទួលបានគម្រោងអនុវត្តកម្មវិធី **គ.ស.ឧ.** ត្រូវបង្កភាពងាយស្រួលនិងសហការជាមួយ **គ.ម.គ.ស.ឧ.** ឬលេខាធិការដ្ឋាននៃ **គ.ម.គ.ស.ឧ.** ក្នុងការចុះត្រួតពិនិត្យនិងតាមដានការអនុវត្តគម្រោងរបស់បុគ្គលទទួលបានគម្រោងអនុវត្តកម្មវិធី **គ.ស.ឧ.** និងឆ្លើយតបទៅនឹងបញ្ហាផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងការអនុវត្តគម្រោង។

ក្នុងករណីដែលគម្រោងអនុវត្តកម្មវិធី **គ.ស.ឧ.** ណាមួយមិនដំណើរការ ឬដំណើរការពុំស្របតាមផែនការសកម្មភាព លេខាធិការដ្ឋាននៃ **គ.ម.គ.ស.ឧ.** ត្រូវធ្វើរបាយការណ៍ជូន **គ.ម.គ.ស.ឧ.** ព្រមទាំងស្នើសុំចាត់វិធានការបន្ទាន់ដើម្បីផ្អាកឬបញ្ឈប់ការអនុវត្តគម្រោងអនុវត្តកម្មវិធី **គ.ស.ឧ.**។

**មាត្រា២៩ ..**

លេខាធិការដ្ឋាននៃ **គ.ម.គ.ស.ឧ.** ត្រូវរៀបចំជាប្រចាំនូវរបាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍ស្ដីពីស្ថានភាពនៃការអនុវត្តកម្មវិធីមូលនិធិ **គ.ស.ឧ.** ដាក់ជូន **គ.ម.គ.ស.ឧ.** ដើម្បីពិនិត្យនិងសម្រេច។

## ជំពូកទី៦
## ទោសប្បញ្ញត្តិ

**មាត្រា៣០ ..**

ក្នុងករណីពិនិត្យឃើញថា ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ **ក.ស.ឧ.** ដើម្បីអនុវត្តគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.** មិនអនុវត្តតាមកាតព្វកិច្ចណាមួយដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ឬបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត **ក.ម.ក.ស.ឧ.** អាចស្នើសុំទៅ **ក.ប.ឧ.** ដើម្បីចាត់វិធានការ ជាអាទិ៍ ដូចខាងក្រោម៖

ក- ដឹកនាំកែតម្រូវប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ **ក.ស.ឧ.** ដើម្បីអនុវត្តគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.**ឱ្យអនុវត្តតាមលក្ខខណ្ឌ ឬលក្ខខណ្ឌបន្ថែម

ខ- បង្អាកការនាំចេញឬការនាំចូលគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍

គ- បង្កកគណនីរបស់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ **ក.ស.ឧ.** ដើម្បីអនុវត្តគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.**

ឃ- ដាក់កំហិតលើអាជ្ញាបណ្ណ

ង- ព្យួរអាជ្ញាបណ្ណ

ច- ព្យួរបណ្តោះអាសន្ន ឬបញ្ឈប់ការងាររបស់អគ្គនាយក នាយកប្រតិបត្តិ សមាជិកគណៈគ្រប់គ្រង ឬបុគ្គលិកជាន់ខ្ពស់របស់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ **ក.ស.ឧ.** ដើម្បីអនុវត្តគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.**

ឆ- ជ្រើសរើសនិងផ្តល់អំណាចដល់បុគ្គលដែលមានសមត្ថកិច្ចសមស្រប ដើម្បីពិនិត្យមើលសកម្មភាពអាជីវកម្ម ឬសកម្មភាពពាក់ព័ន្ធផ្សេងទៀតរបស់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ **ក.ស.ឧ.** ដើម្បីអនុវត្តគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.**

ជ- ដាក់កំហិត ឬបញ្ឈប់សកម្មភាពជាក់លាក់ ឬទូទៅរបស់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ **ក.ស.ឧ.** ដើម្បីអនុវត្តគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.**

ឈ- ចាត់វិធានការផ្សេងទៀតតាមការចាំបាច់ ស្របតាមការកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**មាត្រា៣១ ..**

ដោយពុំទាន់គិតដល់ទណ្ឌកម្មព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត បុគ្គលដែលទទួលបានមូលនិធិ **ក.ស.ឧ.** ដើម្បីអនុវត្តគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.** ដែលប្រើប្រាស់មូលនិធិ **ក.ស.ឧ.** ក្នុងស្ថានភាពមិនសមស្រប ឬ/និងធ្វើឱ្យបាត់បង់ដោយប្រការណាមួយតាមរយៈការលួចកិបកេង ក្លែងបន្លំ ប្រើប្រាស់មូលនិធិ **ក.ស.ឧ.** ខុសគោលដៅ ឬអនុវត្តគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.** មិនត្រឹមត្រូវ, **ក.ម.ក.ស.ឧ.** អាចស្នើសុំទៅ **ក.ប.ឧ.**ដើម្បីចាត់វិធានការ សមស្របដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន។

បុគ្គលដែលទទួលបានមូលនិធិ **ក.ស.ឧ.** ដើម្បីអនុវត្តគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.** ដែលប្រើប្រាស់មូលនិធិ **ក.ស.ឧ.** មិនសមស្រប ឬ/និងធ្វើឱ្យបាត់បង់ដោយប្រការណាមួយ ត្រូវសងមកវិញនូវចំនួនទឹកប្រាក់ដែលទទួលបានពី **ក.ម.ក.ស.ឧ.** ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីទទួលបានសេចក្តីសម្រេចរបស់ **ក.ម.ក.ស.ឧ.** ដោយភ្ជាប់នូវការប្រាក់ដែលកំណត់ដោយច្បាប់គិតចាប់ពីថ្ងៃប្រព្រឹត្តល្មើស។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា៣២**.-

ក្នុងករណីដែលប្រតិបត្តិករទូរគមនាគមន៍ ខកខានមិនបានស្នើសុំការទូទាត់ជាមុនរវាងវិភាគទានមូលនិធិ **ក.ស.ឧ.** ជាមួយនឹងគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.** ដូចកំណត់ក្នុងមាត្រា១៨ នៃអនុក្រឹត្យនេះ ប្រតិបត្តិករទូរគមនាគមនាគមន៍ក៏អាចស្នើសុំការទូទាត់ចំនួន ៥០% (ហាសិបភាគរយ) នៃកាតព្វកិច្ចបង់វិភាគទានមូលនិធិ **ក.ស.ឧ.** ប្រចាំឆ្នាំ។

ការស្នើសុំទូទាត់ក្នុងន័យនៃមាត្រានេះ អនុវត្តចំពោះតែគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.** ដែលកំពុងដំណើរការ ឬត្រូវបានសម្រេចក្នុងឆ្នាំ២០១៧ ឬឆ្នាំ២០១៨ ប៉ុណ្ណោះ។

ដើម្បីអាចស្នើសុំការទូទាត់រវាងវិភាគទានមូលនិធិ **ក.ស.ឧ.** ជាមួយនឹងគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.** ដូចមានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើ ប្រតិបត្តិករទូរគមនាគមន៍ ត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវដាក់ពាក្យស្នើសុំទៅ **ក.ម.ក.ស.ឧ.** យ៉ាងយូរត្រឹមត្រីមាសទីមួយនៃឆ្នាំ២០១៨ សម្រាប់គម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.** ឆ្នាំ២០១៧ ឬត្រីមាសទីមួយនៃឆ្នាំ២០១៩ សម្រាប់គម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.** ឆ្នាំ២០១៨
- ត្រូវភ្ជាប់នូវរបាយការណ៍បច្ចេកទេសលម្អិតនៃគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.** ដែលកំពុងដំណើរការ ឬត្រូវបានសម្រេចរួចហើយ
- ត្រូវភ្ជាប់នូវរបាយការណ៍ហិរញ្ញវត្ថុនៃគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.** ដែលត្រូវបានធ្វើសវនកម្មរួចដោយសវនករឯករាជ្យ ដែលទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ត្រូវគោរពតាមផែនការសកម្មភាពនៃផែនការអនុវត្តកម្មវិធី **ក.ស.ឧ.** ដែលត្រូវបានអនុម័តរួច
- ត្រូវអនុវត្តកាតព្វកិច្ចទាំងឡាយដូចមានកំណត់ក្នុងមាត្រា២៤ នៃអនុក្រឹត្យនេះ និង
- តាមការកំណត់ផ្សេងទៀតដោយ **ក.ម.ក.ស.ឧ.**។

បញ្ញត្តិនៃកថាខណ្ឌទី១ ទី២ និងទី៣ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះប្រតិបត្តិករទូរគមនា-គមន៍ដែលបានស្នើសុំការទូទាត់ជាមុនរវាងវិភាគទានមូលនិធិ **ក.ស.ឧ.** ជាមួយនឹងគម្រោងអនុវត្តកម្មវិធី **ក.ស.ឧ.** ដែលកំណត់ក្នុងមាត្រា១៨ នៃអនុក្រឹត្យនេះ។

**មាត្រា៣៣**.-

ប្រតិបត្តិករទូរគមនាគមន៍ត្រូវបង់វិភាគទានសម្រាប់ឆ្នាំ២០១៧ ដោយផ្អែកលើចំណូលដុលប្រចាំឆ្នាំ២០១៦ មក **ក.ម.ក.ស.ឧ.**។

**ក.ម.ក.ស.ឧ.** ត្រូវកំណត់កាលបរិច្ឆេទនៃការបង់វិភាគទានសម្រាប់ឆ្នាំ២០១៧។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា៣៤**.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៣៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ